# =|មុនពេលសម្ភាសន៍|=

## សារគន្លឹះ ១

### បង្កើតភាពស្និទ្ធស្នាល ជាមួយនឹងអ្នកឆ្លើយសំណួរ

ចាប់ផ្តើមដោយពាក្យ "ជម្រាបសួរ" ណែនាំខ្លួន និងគោលបំណងសម្ភាសន៍ ទៅកាន់អ្នកឆ្លើយសំណួរ។

ឧទាហរណ៍៖ ជម្រាបសួរ បងស្រី! នាងខ្ញុំឈ្មោះ បុប្ផា។ នាងខ្ញុំគឺជាតំណាងឲ្យក្រសួងផែនការ/ក្រសួងសុខាភិបាល ដើម្បីចុះធ្វើសម្ភាសន៍ស្តីអំពី "បញ្ហាសុខភាពរបស់ស្ត្រី" នៅទូទាំងប្រទេសកម្ពុជា។ នាងខ្ញុំសុំពេលជួបជជែកជាមួយនឹងបងស្រី និងសាកសួរនូវសំណួរមួយចំនួន។

## សារគន្លឹះ ២

### បញ្ជាក់បន្ថែម អំពីការរក្សាទុកចម្លើយជាសម្ងាត់

បញ្ជាក់ទៅអ្នកឆ្លើយសំណួរឲ្យបានច្បាស់ថា ព័ត៌មានដែលប្រមូលបាន នឹងត្រូវរក្សាទុកជាសម្ងាត់ ហើយឈ្មោះរបស់អ្នកឆ្លើយសំណួរមិនត្រូវបានយកមកបង្ហាញឡើយ។

**កំណត់សំគាល់:** អ្នកមិនត្រូវបរិយាយអំពីចម្លើយ ឬបង្ហាញបញ្ជីសំណួរដែលបានសួររួចទៅដល់មន្ត្រី ឬប្រធានក្រុមសម្ភាសន៍ នៅចំពោះមុខអ្នកឆ្លើយសំណួរ ឬមនុស្សដទៃទៀតឡើយ។

## សារគន្លឹះ ៣

### ត្រៀមចម្លើយ សម្រាប់ចម្ងល់របស់អ្នកឆ្លើយសំណួរ

ប្រសិនបើអ្នកឆ្លើយសំណួរមានចម្ងល់ផ្សេងៗដូចជាបញ្ហាសុខភាពស្ត្រី ការពន្យារកំណើត កន្លែងផ្តល់សេវា ជាដើម។ល។ គួរពន្យល់គាត់ថា នឹងព្យាយាមឆ្លើយសំណួរទាំងនោះនៅពេលក្រោយ ពីព្រោះមានសំណួរខ្លះដែលគាត់ចង់ដឹង អាចនឹងមានចម្លើយសមស្របស្រាប់នៅសំណួរបន្តបន្ទាប់។

**កំណត់សំគាល់:** ក្នុងករណីអ្នកឆ្លើយសំណួរចង់ដឹងថា ហេតុអ្វីបានជាគាត់ត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍ចូរពន្យល់គាត់ថា សម្ភាសន៍នេះត្រូវបានធ្វើឡើងតាមវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ និងកំពុងតែប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជា។

## សារគន្លឹះ ៤

### រកកន្លែងមានសុវត្ថិភាព មុនធ្វើសម្ភាស បញ្ជីសំណួរ"អំពើហិង្សាក្នុងគ្រួសារ"

សង្កេតមើលនៅជុំវិញខ្លួន ដើម្បីប្រាកដថា មិនមាននរណាអាចស្តាប់ឮកិច្ចសន្ទនាក្នុងពេលសម្ភាសន៍ឡើយ។ ប្រសិនបើមានមនុស្សដទៃអាចស្តាប់ឮ ទោះជាបុរសក្តី ស្ត្រីក្តី ឬជាកូនក្តី (អាយុលើល២ឆ្នាំ) អ្នកមិនត្រូវចាប់ផ្តើមធ្វើសម្ភាសន៍បញ្ជីសំណួរ "អំពើហិង្សាក្នុងគ្រួសារ" ឡើយ។

**កំណត់សំគាល់:** បើសង្កេតឃើញថា កាលៈទេសៈមិនអំណោយផលសម្រាប់សម្ភាសន៍ ឬមិនអាចរកទីកន្លែងសមស្របបាន អ្នកអាចសុំណាត់ជួបជាមួយអ្នកឆ្លើយសំណួរម្តងទៀតនៅពេលក្រោយ ក្នុងអំឡុងពេលកំពុងចុះធ្វើសម្ភាសន៍នៅតំបន់នោះ។

# =|ក្នុងពេលសម្ភាសន៍|=

## សារគន្លឹះ ៥

### ត្រូវប្រាកដថា អ្នកឆ្លើយសំណួរ យល់សំណួរបានច្បាស់

គួរសួរសំណួរឲ្យបានច្បាស់ និងមួយៗដើម្បីឲ្យអ្នកឆ្លើយសំណួរអាចយល់បាន ព្រមទាំងទុកពេលឲ្យគាត់គិតពិចារណាសិន មុននឹងឲ្យគាត់ផ្តល់ចម្លើយ។ ការសួរសំណួរលឿនពេក ធ្វើឲ្យគាត់អាចនឹករកចម្លើយមិនទាន់ ហើយនាំឲ្យគាត់ឆ្លើយថា "ខ្ញុំមិនដឹងទេ" ឬផ្តល់ចម្លើយមិនបានចំ។

**កំណត់សំគាល់:** បើសង្កេតឃើញថា អ្នកឆ្លើយសំណួរផ្តល់ចម្លើយលឿនពេក ដោយសារគាត់ចង់ឲ្យឆាប់ចប់ អ្នកអាចប្រាប់គាត់វិញថា៖ "បងស្រី! បងពុំចាំបាច់ប្រញាប់ប្រញាល់ឆ្លើយសំណួរលឿនពេកទេ ដោយសារចម្លើយរបស់បងស្រីមានសារៈសំខាន់ខ្លាំងណាស់។ បងស្រី អាចចំណាយពេលគិតពិចារណាសិន មុននឹងផ្តល់ចម្លើយ។

## សារគន្លឹះ ៦

### ជៀសវាងជួយផ្តល់ចម្លើយ ទៅឲ្យអ្នកឆ្លើយសំណួរ

អ្នកគួរជៀសវាងនិយាយប្រយោគដូចជា "ខ្ញុំគិតថា បងស្រីចង់និយាយថា... តើត្រូវដែរទេ?" ក្នុងករណីដែលអ្នកឆ្លើយសំណួរឆ្លើយមិនបានចំសំណួរ។ ជាទូទៅ អ្នកឆ្លើយសំណួរនឹងយល់ស្របទៅតាមការបញ្ជាក់របស់អ្នក ទោះបីជាចម្លើយនោះមិនមែនជាអ្វីដែលគាត់ចង់និយាយក៏ដោយ ។ វិធីដែលល្អ អ្នកគួរបំផុសសំណួរបញ្ជាក់ ដើម្បីឲ្យគាត់ពន្យល់បន្ថែមលើចម្លើយ។ អ្នកគួរជៀសវាងអានចម្លើយដែលមានស្រាប់ក្នុងបញ្ជីសំណួរឲ្យអ្នកឆ្លើយសំណួស្តាប់ ទោះបីជាអ្នកឆ្លើយសំណួរនោះមានការលំបាកក្នុងការឆ្លើយសំណួរក៏ដោយ។

## =|ក្នុងពេលសម្ភាសន៍|=

### សារគន្លឹះ ៧

#### រៀបចំឥរិយាបថ សមស្របពេលសម្ភាសន៍ និងប្រកាន់ “គោលជំហរជាកណ្ដាល ”ជានិច្ច

អ្នកគួរអង្គុយនៅស្មើ ហើយជាប់នឹងអ្នកឆ្លើយសំណួរ ព្រមទាំងប្រើពាក្យសំដី និងមានឥរិយាបថទន់ភ្លន់ ដើម្បីឲ្យអ្នកឆ្លើយសំណួរមានអារម្មណ៍កក់ក្ដៅក្នុងចិត្ត ក្នុងពេលសម្ភាសន៍។ អ្នកពុំគួរបញ្ចេញកាយវិការ ទឹកមុខ ឬនិយាយអ្វីដែលនាំឲ្យអ្នកឆ្លើយសំណួរមានអារម្មណ៍ថា គាត់ឆ្លើយសំណួរអ្វីមួយបាន“ត្រូវ”ឬ “ខុស”ឡើយ។ អ្នកគួរជៀសវាងបង្ហាញឥរិយាបថទាំងឡាយណាដែលធ្វើឲ្យគាត់ដឹងថា អ្នកយល់ស្រប ឬមិនយល់ស្របចំពោះចម្លើយរបស់គាត់។

### សារគន្លឹះ ៨

#### ត្រូវរក្សាខ្លឹមសារ និងលំដាប់លំដោយ របស់សំណួរក្នុងបញ្ជីសំណួរ

ក្នុងករណីអ្នកឆ្លើយសំណួរ យល់សំណួរខុស អ្នកគួរសួរសំណួរនោះឡើងវិញ ដោយយឺតៗ និងច្បាស់លាស់។ ប្រសិនជាគាត់នៅតែមិនយល់ អ្នកអាចសម្រួលពាក្យរបស់សំណួរដើម្បីឲ្យងាយយល់ ប៉ុន្តែមិនត្រូវឲ្យខុសអំពីខ្លឹមសារដើមរបស់សំណួរឡើយ។ អ្នកត្រូវផ្ដល់តែព័ត៌មានណាដែលចាំបាច់ និងខ្លីបំផុត ដើម្បីឲ្យអ្នកឆ្លើយសំណួរអាចផ្ដល់ចម្លើយបានត្រឹមត្រូវ។

## =|ក្រោយពេលសម្ភាសន៍|=

### សារគន្លឹះ ៩

#### ពិនិត្យបញ្ជីសំណួរឡើងវិញ និងបំពេញព័ត៌មានណាដែលនៅខ្វះចន្លោះ

នៅពេលដែលធ្វើសម្ភាសន៍ចប់ អ្នកគួរព្យាយាមរកមើលព័ត៌មានណាដែលខ្វះចន្លោះដើម្បីបំពេញបន្ថែម ប៉ុន្តែមិនត្រូវបង្ខំអ្នកឆ្លើយសំណួរឲ្យផ្ដល់ចម្លើយ ឬព័ត៌មានដែលនៅខ្វះចន្លោះនោះឡើយ។

**កំណត់សំគាល់:** បន្ទាប់ពីសម្ភាសន៍ចប់អ្នកមិនត្រូវបង្ហាញបញ្ជីសំណួរទៅនរណាម្នាក់ រួមទាំងអ្នកឆ្លើយសំណួរ ដោយគ្មានការអនុញ្ញាតពីប្រធានក្រុមសម្ភាសន៍របស់អ្នក ឬអ្នកពិនិត្យបញ្ជីសំណួរសម្ភាសន៍នោះឡើយ។ ប្រសិនបើអ្នកឆ្លើយសំណួរចង់មើល ឬអានចម្លើយនៅក្នុងបញ្ជីសំណួរ អ្នកគួរបដិសេធប្រកបដោយភាពទន់ភ្លន់ ដោយមិនត្រូវផ្ដល់ឯកសារនេះទៅគាត់ឡើយ។

### សារគន្លឹះ ១០

#### ថ្លែងអំណរគុណ ដល់អ្នកឆ្លើយសំណួរ បន្ទាប់ពីសម្ភាសន៍ចប់:

ពេលដែលអ្នកធ្វើសម្ភាសន៍ចប់ ចូរថ្លែងអំណរគុណទៅដល់អ្នកឆ្លើយសំណួរ ចំពោះការសហការចូលរួម និងការចំណាយពេលវេលារបស់គាត់ ព្រមទាំងបញ្ជាក់ឡើងវិញអំពីការរក្សាទុកជាសម្ងាត់ និងសារៈសំខាន់នៃចម្លើយរបស់គាត់ ដែលមានប្រយោជន៍ដល់ស្ត្រីទាំងអស់ក្នុងប្រទេសកម្ពុជា។

**កំណត់សំគាល់:** ក្នុងករណីមានការរំខានណាមួយក្នុងពេលសម្ភាសន៍ ហើយមិនអាចបញ្ចប់សំណួរ អ្នកត្រូវណាត់ពេលវេលាសារជាថ្មី ជាមួយនឹងអ្នកឆ្លើយសំណួរ ។

# សារគន្លឹះ ទាំង ១០

## សម្រាប់ជំនួយស្មារតីនៅ:

- មុនពេល...
- ក្នុងពេល...
- និង ក្រោយពេល...

## សម្ភាសន៍បញ្ជីសំណួរ

# “អំពើហិង្សាក្នុងគ្រួសារ ”

### រៀបចំដោយ

ក្រសួងផែនការ

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងសុខាភិបាល

អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល

### ឧបត្ថម្ភដោយ

UNFPA · Australian Aid · USAID FROM THE AMERICAN PEOPLE · unicef unite for children · JICA · KOICA Korea International Cooperation Agency · World Health Organization · HSSP-2 · ICF MACRO an ICF International Company

# 我们的产品

云报告

## 大数据平台

国内宏观经济数据库

国际经济合作数据库

行业分析数据库

## 条约法规平台

国际条约数据库

国外法规数据库

## 即时信息平台

新闻媒体即时分析

社交媒体即时分析

## 云报告平台

## 数据智慧平台

预览已结束，完整报告链接和二维码如下：

https://www.yunbaogao.cn/report/index/report?reportId=5_19539